**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**KINGDOM OF CAMBODIA**
***Nation - Religion - King***

**ក្រសួងពាណិជ្ជកម្ម**
*Ministry of Commerce*

លេខ ០៣៦៦ ព.ណ.ករម.....

ភ្នំពេញ, ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៦.....

**ជម្រាបមក**

**លោក/លោកស្រីប្រធានក្រុមហ៊ុន ឡា ហ្វ្រង់ មើឆិនដាយហ្ស៊ីង អ៊ីមផត អិចផត**

**កម្មវត្ថុ:** ការកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើផលិតផលស្បែក ស្បែកសិប្បនិម្មិត និងទំនិញដែលផលិតពីស្បែកទាំងនេះ ដោយមិនរាប់បញ្ចូលទំនិញនៅក្នុងជំពូកដទៃទៀតឡើយ ស្បែកសត្វ ស្បែក ហិប និងការបូបធ្វើដំណើរ ឆ័ត្រ ក្លស់ ឈើច្រត់ ខ្សែតី អានសេះ និងគ្រឿងសេះ ម៉ាក MONTAGUT ក្នុងព្រះរាជាណាចក្រកម្ពុជា របស់ក្រុមហ៊ុន **ឡា ហ្វ្រង់ មើឆិនដាយហ្ស៊ីង អ៊ីមផត អិចផត** ។

**យោង:** - មាត្រា ៣ និងមាត្រា ១១ នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- លិខិតរបស់ក្រុមហ៊ុន **ឡា ហ្វ្រង់ មើឆិនដាយហ្ស៊ីង អ៊ីមផត អិចផត** ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៦
- លិខិតប្រគល់សិទ្ធិផ្តាច់មុខរបស់ក្រុមហ៊ុន BONNETERIE CEVENOLE ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៥
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មី ដែលលេខចុះបញ្ជីដើម KH/៩៦/៩២ ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១២ ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោក/លោកស្រីប្រធានថា ក្រសួងពាណិជ្ជកម្មឯកភាពកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើផលិតផលស្បែក ស្បែកសិប្បនិម្មិត និងទំនិញដែលផលិតពីស្បែកទាំងនេះ ដោយមិនរាប់បញ្ចូលទំនិញនៅក្នុងជំពូកដទៃទៀតឡើយ ស្បែកសត្វ ស្បែក ហិប និងការបូបធ្វើដំណើរ ឆ័ត្រ ក្លស់ ឈើច្រត់ ខ្សែតី អានសេះ និងគ្រឿងសេះពាក់ម៉ាកខាងលើក្នុងព្រះរាជាណាចក្រកម្ពុជា របស់ក្រុមហ៊ុន **ឡា ហ្វ្រង់ មើឆិនដាយហ្ស៊ីង អ៊ីមផត អិចផត** ដែលទទួលបានពីក្រុមហ៊ុន BONNETERIE CEVENOLE ដូចមានចែងក្នុងលិខិតប្រគល់សិទ្ធិនាំចូលផ្តាច់មុខរបស់ម្ចាស់ម៉ាក ដែលក្រសួងបានតម្កល់ទុករួចហើយ ។

លិខិតកត់ត្រានេះ មានសុពលភាព ០២(ពីរ)ឆ្នាំ ដោយគិតចាប់ពីក្រោយថ្ងៃចុះហត្ថលេខាចំនួន ៩០(កៅសិប) ថ្ងៃ ហើយអាចនឹងត្រូវបាត់បង់សុពលភាពជាស្វ័យប្រវត្តិវិញ មុនកាលបរិច្ឆេទផុតកំណត់ខាងលើ ប្រសិនបើមានការជូនដំណឹងអំពីការបញ្ចប់សិទ្ធិពីក្រុមហ៊ុន BONNETERIE CEVENOLE ដែលជាម្ចាស់ម៉ាក ។

នីតិបុគ្គលដែលទទួលបានសិទ្ធិនាំចូល និងចែកចាយផ្តាច់មុខ ត្រូវបោះពុម្ពផ្សាយលិខិតកត់ត្រានេះក្នុងទំព័រខាងមុខសារព័ត៌មានល្បីៗភ្លាមយ៉ាងតិចចំនួន ៣(បី) លេខជាប់ៗគ្នា និងត្រូវអនុវត្តឲ្យបានត្រឹមត្រូវនូវលិខិតបទដ្ឋានគតិយុត្តិ ជាធរមាន។

អាស្រ័យហេតុនេះ សូមលោក/លោកស្រីប្រធានក្រុមហ៊ុន ជ្រាបជាព័ត៌មាន ។

**ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**រដ្ឋលេខាធិការ**

**អ៊ុក-ប្រជា**

<u>ចម្លងជូន:</u>
- ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
- ខុទ្ទកាល័យ **សម្តេចក្រឡាហោម ស ខេង**
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ **គាត ឈន់**
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គនាយកដ្ឋានកាំកុងត្រូល
- អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា
- អគ្គនាយកដ្ឋានពន្ធដារ
- ឯកសារ - កាលប្បវត្តិ

ឡូត៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
*Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA*
ទូរស័ព្ទ / ទូរសារ:(៨៥៥)-២៣ ៨៦៦ ៤៦៩
*Phone/Facsimile: (855)-23 866 469*